# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
លេខចូល 0478
ថ្ងៃទី: 5.2.24 ម៉ោង 3:48
បញ្ជូន: ថ្ងៃទី:

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់នៃការងារ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.អ.ទ.** ដើម្បីដឹកនាំជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា។

## ជំពូកទី២
## សមាសភាពនៃ គ.ជ.អ.ឧ.

**មាត្រា២ .-**

**គ.ជ.អ.ឧ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - ទេសរដ្ឋមន្ត្រី ១រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |



៤

- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក
- តំណាងក្រសួងទេសចរណ៍ ១០រូប សមាជិក
- ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត សមាជិក
- ប្រធានលេខាធិការដ្ឋាន **គ.ជ.អ.ទ.** សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ជ.អ.ទ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ជ.អ.ទ.** អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័ន ពាក់ព័ន្ធផ្សេងៗទៀត នៃរាជរដ្ឋាភិបាល តាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចនៃ គ.ជ.អ.ទ.

**មាត្រា៣.-**

**គ.ជ.អ.ទ.** មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលនិងមានភារកិច្ចដូចខាងក្រោម៖

- សហការដឹកនាំ សម្របសម្រួល និងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា
- សម្របសម្រួលនិងជំរុញការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍
- សម្របសម្រួលនិងជំរុញលើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីវិស័យទេសចរណ៍ ពិសេសផលប៉ះពាល់នៃវិស័យនេះទៅលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- សហការលើកគំនិតផ្តួចផ្តើមនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលអំពីទស្សនទាន ជម្រើសគោលនយោបាយ ការកែទម្រង់ ការកំណត់ទិសដៅ គោលដៅ ចក្ខុវិស័យនៃការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ ឱ្យកាន់តែមានប្រសិទ្ធភាព
- សហការជំរុញតាមដានការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ពាក់ព័ន្ធនឹងវិស័យទេសចរណ៍ និងរៀបចំរបាយការណ៍បូកសរុបការងារអនុវត្ត ស្ថានភាពទេសចរណ៍ លើកយោបល់ឬដំណោះស្រាយ ព្រមទាំងវិធានការនានាជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេច
- ពិនិត្យ សម្រេច និងគ្រប់គ្រងគម្រោងផែនការសកម្មភាពរបស់ **គ.ជ.អ.ទ.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។



៤

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ គ.ជ.អ.ទ.

**មាត្រា៤ .-**

ប្រធាន **គ.ជ.អ.ទ.** ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់រៀងរាល់ដំណាច់ឆមាសនីមួយៗ។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធាន ណាមួយដែលបានទទួលសិទ្ធិពីប្រធាន ត្រូវដឹកនាំការប្រជុំរបស់ **គ.ជ.អ.ទ.**។

**មាត្រា៥ .-**

ប្រធាន **គ.ជ.អ.ទ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជន ចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់ការងារទាំងឡាយដែលទាក់ទងនឹង **គ.ជ.អ.ទ.**។

**មាត្រា៦ .-**

**គ.ជ.អ.ទ.** មានសិទ្ធិបង្កើតគណៈកម្មការ ក្រុមការងារបច្ចេកទេស ឬក្រុមពិគ្រោះយោបល់តាមការចាំបាច់ ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍវិស័យទេសចរណ៍ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

**គ.ជ.អ.ទ.** ត្រូវបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត ដែលត្រូវកំណត់ដោយ សេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

**មាត្រា៧ .-**

**គ.ជ.អ.ទ.** មានអង្គភាពមួយនៃក្រសួងទេសចរណ៍ ជាលេខាធិការដ្ឋាន **គ.ជ.អ.ទ.** តាមការសម្រេច របស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ជ.អ.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ ប្រធាន **គ.ជ.អ.ទ.**។

សមាសភាពជាក់ស្តែងរបស់លេខាធិការដ្ឋាន **គ.ជ.អ.ទ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.** តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៨ .-**

**គ.ជ.អ.ទ.** មានត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ប្រភពធនធាននៃ គ.ជ.អ.ទ.

**មាត្រា៩ .-**

**គ.ជ.អ.ទ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌ ថវិកាប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍។

**គ.ជ.អ.ទ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធានស្របច្បាប់ផ្សេងៗទៀតតាមការកំណត់ របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។



ᑫ

# ជំពូកទី៦
# អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

អនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៤
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## ត្រារបស់ គ.ជ.អ.ទ.

ព្រះរាជាណាចក្រកម្ពុជា

គ.ជ.អ.ទ.

គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍